ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល

MINISTRY OF ECONOMY AND FINANCE

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវឆាតបិត «CamInvoice Chatbot» នៅលើបណ្តាញតេឡេក្រាម (Telegram)

អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជម្រាបជូនសាធារណជន និងសមាជិកជាអ្នកប្រើប្រាស់នៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា (**ប.ទ.អ.**) ទាំងអស់ឱ្យបានជ្រាបថា៖ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការគាំទ្រ និងផ្តល់ព័ត៌មានជូនសាធារណជន និងអ្នកប្រើប្រាស់ **ប.ទ.អ.**, អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ដែលជាប្រតិបត្តិករនៃ **ប.ទ.អ.** បានរៀបចំ និងដាក់ឱ្យដំណើរការជាផ្លូវការនូវឆាតបិត «CamInvoice Chatbot» នៅលើបណ្តាញតេឡេក្រាមចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ការដាក់ដំណើរការឆាតបិតនេះនឹងជួយសម្រួលដល់ការគាំទ្រ និងការផ្តល់ព័ត៌មានផ្សេងៗអំពី **ប.ទ.អ.** ដោយអនុញ្ញាតឱ្យសាធារណជន និងសមាជិកជាអ្នកប្រើប្រាស់អាចប្រើប្រាស់ឆាតបិតនេះដើម្បីស្វែងរកព័ត៌មានទូទៅ និងដំណោះស្រាយទៅលើបញ្ហាបឋមមួយចំនួននៅលើ **ប.ទ.អ.**។

អាស្រ័យហេតុនេះ សូមសាធារណជន និងសមាជិកជាអ្នកប្រើប្រាស់នៃ **ប.ទ.អ.** ទាំងអស់ មេត្តាជ្រាប និងអញ្ជើញចូលរួមប្រើប្រាស់ឆាតបិតនេះ តាមតម្រូវការជាក់ស្តែង ដោយគ្រាន់តែធ្វើការស្កេន QR Code ខាងក្រោមនេះ។

ថ្ងៃ ព្រហស្បតិ៍ ៤កើត ខែបុស្ស ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០២៦

ព្រះរាជាណាចក្រកម្ពុជា
អគ្គនាយកដ្ឋាន សេដ្ឋកិច្ចឌីជីថល
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សូមស្កេនដើម្បីចូលប្រើប្រាស់
CamInvoice Chatbot នៅលើបណ្តាញតេឡេក្រាម

មជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច, ជាន់ទី៧, វិថី OCIC, សង្កាត់ជ្រោយចង្វារ, ខណ្ឌជ្រោយចង្វារ, រាជធានីភ្នំពេញ
BDC, 7th Floor, OCIC Blvd, Sangkat Chroy Changva, Khan Chroy Changvar, Phnom Penh, CAMBODIA
mef.gov.kh
t.me/mef_gdde
ទូរសព្ទ:(+៨៥៥) ១៥ ៨៨១ ៦១១
Phone : (+855) 15 881 611
info@mef.gov.kh
gdde_admin@mef.gov.kh